ខិត្តប័ណ្ណព័ត៌មាន

# បញ្ហាប្រឈមទាក់ទងនឹងយេនឌ័ររបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រីនៅជួរមុខ



## ០១ តើអ្នកការពារសិទ្ធិមនុស្សជាស្ត្រីជានរណា?

អ្នកការពារសិទ្ធិមនុស្សជាស្ត្រី គឺជាស្ត្រី និងក្មេងស្រីដែលធ្វើសកម្មភាពផ្តោតលើបញ្ហាសិទ្ធិមនុស្ស ក្នុងនោះរួមបញ្ចូលទាំងបុគ្គលដែលមានយេនឌ័រផ្សេងទៀត ដែលកំពុងធ្វើការងារដើម្បីលើកកម្ពស់សិទ្ធិស្ត្រី និងសមភាពយេនឌ័រក្នុងតវិយាបថអហិង្សា។

## ឧទាហរណ៍



ស្ត្រីជនជាតិដើមភាគតិចទាមទារឱ្យមានការគោរពសិទ្ធិដីធ្លី និងបរិស្ថាន



អ្នកស្រឡាញ់ភេទដូចគ្នាចេញមុខប្រឆាំងនឹងការរើសអើង



អ្នកសារព័ត៌មានជាស្ត្រីរាយការណ៍ពីបញ្ហាទាក់ទងនឹងផលប្រយោជន៍សាធារណៈ

អ្នកការពារសិទ្ធិមនុស្សជាស្ត្រី បាននឹងកំពុងធ្វើការងារដ៏ស្វាហាប់ដើម្បីសិទ្ធិមនុស្សជាច្រើនទសវត្សរ៍កន្លងមកហើយ ជាពិសេស សិទ្ធិស្ត្រី និងក្មេងស្រី ដោយសារតែមានការរើសអើង និងអំពើហិង្សាកើតឡើងច្រើនប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់ពួកគេ។

អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ធ្វើការងារនៅគ្រប់ទីកន្លែង ទាំងនៅថ្នាក់អន្តរជាតិ ថ្នាក់តំបន់ ក្នុងប្រទេស និងនៅថ្នាក់មូលដ្ឋានដែលអ្នកស្រី អេលីណ័រ រ៉ូស្វែល ហៅទីនោះថាជា «ទីកន្លែងដ៏តូច នៅជិតផ្ទះបំផុត»។



# ០២ ក្របខ័ណ្ឌច្បាប់

នៅក្នុងប្រទេសកម្ពុជា អ្នកការពារសិទ្ធិមនុស្សជាស្ត្រីទាំងអស់មានសិទ្ធិក្នុងការបំពេញសកម្មភាពរបស់ខ្លួន ដើម្បីសម្រេចបាននូវទិសដៅរបស់ខ្លួន ពោលគឺ ការសម្រេចបាននូវសិទ្ធិមនុស្ស រួមបញ្ចូលទាំងសិទ្ធិស្ត្រី និងក្មេងស្រី។ សិទ្ធិរបស់ពួកគេត្រូវបានលើកកម្ពស់ និងការពារ នៅក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ និងច្បាប់ជាតិ។



## ១ ក្របខ័ណ្ឌច្បាប់អន្តរជាតិ

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី និងពិធីសារបន្ថែម
- សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្ស
- អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពអ្នកការពារសិទ្ធិមនុស្ស
- វេទិកាសកម្មភាពទីក្រុងប៉េកាំង
- សេចក្តីសម្រេចលេខ ៦៨/១៨១ ស្តីពីការលើកកម្ពស់សេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងស្ថាប័នសង្គមក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល៖ ការពារអ្នកការពារសិទ្ធិមនុស្សជាស្ត្រី
- ដំណើរការត្រួតពិនិត្យជាសកលតាមកាលកំណត់ (យូភីអ) ជុំទី៣។



## ២ ក្របខ័ណ្ឌច្បាប់ជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

# ០៣ បញ្ហាប្រឈមទាក់ទង នឹងយេនឌ័រ

នៅប្រទេសកម្ពុជា អ្នកការពារសិទ្ធិមនុស្សជាស្ត្រី នៅជួរមុខតែងចួបប្រទះ បញ្ហាប្រឈមទាក់ទង នឹងយេនឌ័រ

នេះជាបញ្ហាប្រឈមបន្ថែម ទៀតរបស់អ្នកការពារសិទ្ធិ មនុស្សជាស្ត្រី ដែលអ្នក ការពារសិទ្ធិមនុស្សជាបុរស កម្រចួបប្រទះ។

- អំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ
- ការម៉ាក់ងាយដោយសារតែយេនឌ័រ
- ការផាត់ចេញជាលក្ខណៈប្រព័ន្ធ
- ការមិនទទួលស្គាល់ការងាររបស់ពួកគេ
- ការរើសអើងពីសហគមន៍

**មូលហេតុ** >>>> **ផលប៉ះពាល់**

កត្តាដែលធ្វើឱ្យអ្នកការពារសិទ្ធិមនុស្សជាស្ត្រីងាយរងគ្រោះទៅនឹងបញ្ហាប្រឈមផ្សេងទៀតនោះ:

- បទដ្ឋានយេនឌ័រ
- វិសមភាពយេនឌ័រ
- ការយល់ឃើញចំពោះការងាររបស់ពួកគេ

# ០៤ សំណួរទៅកាន់រាជរដ្ឋាភិបាល




ខាងក្រោមនេះ គឺជាសំណួរចំនួន១០ ដែលប្រជាជនកម្ពុជាចង់សាកសួរទាក់ទងនឹងការអនុវត្តសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងសកម្មជនអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា។ គណៈកម្មការបានជ្រើសរើសសំណួរទាំងអស់នោះដោយគោរពទៅតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងការប្រកួតប្រជែងនៅលើប្រព័ន្ធអនឡាញមួយ។

១ ក្នុងយុគសម័យនាពេលបច្ចុប្បន្ន តើរាជរដ្ឋាភិបាលមានយន្តការបែបណាខ្លះក្នុងការការពារការអនុវត្តសិទ្ធិឱ្យមានប្រសិទ្ធភាពក្នុងការលើកកម្ពស់សិទ្ធិនារី ទប់ស្កាត់អំពើហិង្សា ព្រមទាំងសកម្មជនអ្នកស្រលាញ់ភេទដូចគ្នាដែលជាពិសេសនោះគឺយន្តការផ្លូវច្បាប់ក្នុងការទប់ស្កាត់ការរើសអើងសកម្មជនអ្នកស្រលាញ់ភេទដូចគ្នា?

២ តើរដ្ឋាភិបាល មានយន្តការធានា ឬដោះស្រាយអ្វីខ្លះដើម្បីឱ្យមន្ត្រីថ្នាក់ជាតិ និងនៅមូលដ្ឋានអនុវត្តការពារសិទ្ធិស្ត្រី និងការពារសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នាយ៉ាងដូចម្តេច?

៣ តើរដ្ឋាភិបាលមានយុទ្ធសាស្ត្របែបណា ដើម្បីលើកកម្ពស់សិទ្ធិស្ត្រីក្នុងវិស័យនយោបាយ?

៤ តើរដ្ឋាភិបាលបានចាត់វិធានការអ្វីខ្លះដើម្បីឆ្លើយតបនឹងការប្រើហិង្សាលើស្ត្រីសកម្មជននយោបាយ សកម្មសិទ្ធិមនុស្ស សិទ្ធិការងារ?

៥ តើរដ្ឋាភិបាលអាចធ្វើអ្វីបានខ្លះដើម្បីធានាឲ្យមានការអនុវត្តសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងសកម្មជនអ្នកស្រលាញ់ ភេទដូចគ្នា ?

៦ តើរាជរដ្ឋាភិបាលមានយន្តការបែបណា ក្នុងការពង្រីកលម្ហសេរីភាព ដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី និងសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា?

៧ តើរដ្ឋាភិបាលកម្ពុជាមានយុទ្ធសាស្ត្របែបណា ក្នុងការលើកកម្ពស់ស្ត្រីនៅគ្រប់វិស័យចំពោះតួនាទីជាអ្នកដឹកនាំ ឬធ្វើសេចក្តីសម្រេចចិត្ត?

៨ ដោយឃើញនៅក្នុងសង្គមបច្ចុប្បន្នជាក់ស្តែង អ្នកការពារសិទ្ធិមនុស្សជាពិសេសជាស្ត្រីភាគច្រើនត្រូវបានគេមាក់ងាយ មិនឱ្យតម្លៃ និងសរសេរពាក្យប្រមាថតាមបណ្តាញសង្គមអ៊ីនធឺណិត។ តើរដ្ឋាភិបាល អ្នកពាក់ព័ន្ធក៏ដូចជាស្ថាប័នដែលពាក់ព័ន្ធគួរតែមានដំណោះស្រាយយ៉ាងណាចំពោះបញ្ហាទាំងនេះ?

៩ ដើម្បីការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងសមភាពយេនឌ័រ តើអ្វីទៅជាគោលនយោបាយជាក់លាក់របស់ រដ្ឋាភិបាលអាណត្តិទី៧នេះ? ជាពិសេស គោលនយោបាយការពារអ្នកការពារសិទ្ធិមនុស្សជាស្ត្រី?

១០ មូលហេតុអ្វី ស្ត្រីតាមជនបទ មិនបានចូលរួមក្នុងសង្គមភាគច្រើន?

ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈលេខទូរសព្ទលេខ ០២៣ ៧២៦ ៩០១ ឬអ៊ីម៉ែល info@cchrcambodia.org

គាំទ្រដោយ

CFLI/FCIL
Canada Fund for Local Initiatives
Fonds canadien d'initiatives locales

ផលិតដោយ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

CC BY NC SA

ខែធ្នូ ឆ្នាំ២០២៣